# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et Des Sciences Economiques

Royal University of Law and Economics


## គម្រោងស្រាវជ្រាវ

# មុខវិជ្ជា៖ គ្រប់គ្រង និង វិភាគគម្រោង

# កម្មវិធីសប្បុរសធម៌ «មួយថ្ងៃ នៃស្នាមញញឹម»

គម្រោងអនុវត្ត ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦

**សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត ព្រុំ ទេវី**


រៀបរៀងដោយ៖

១.លោក ថៃ សុមេធ

២.កញ្ញា ភី ចិន្តា

៣.កញ្ញា គឹម ស្រីនិច្ច

៤.កញ្ញា មុត នីតា

៥.កញ្ញា ជឹម សុភានូ

៦.លោក ណាំ សុខហៃ

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង

ជំនាន់២២ ជំហាន២ ក្រុមB ឆ្នាំទី១ ឆមាសទី២


ឆ្នាំសិក្សា ៖ ២០២៥-២០២៦

# អារម្ភកថា

ជាដំបូងយើងខ្ញុំ សូមសម្ដែងការគោរពអរគុណ និងមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះអ្នកគ្រូសាស្ត្រាចារ្យ **បណ្ឌិត ព្រុំ ទេវី** ដែលអ្នកគ្រូបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនរូបយើងខ្ញុំ និងបានផ្ដល់ជាប្រធានបទកិច្ចការស្រាវជ្រាវសម្រាប់ឲខ្ញុំបាទបានធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ឲការតែស៊ីជម្រៅបន្ថែមទៀត។

កិច្ចការស្រាវជ្រាវនេះ វាគ្រាន់តែជាការចែករំលែកនូវចំណេះដឹងមួយចំនួនតូច ទៅតាមលទ្ធភាពដែលយើងខ្ញុំធ្លាប់បានធ្វើការស្រាវជ្រាវកន្លងមក និងតាមឯកសារយោងមួយចំនួននៅតាមប្រព័ន្ធអ៊ីធឺណេត។ ខ្ញុំបាទសង្ឃឹមថា កិច្ចការស្រាវជ្រាវនេះនឹងក្លាយជាមូលដ្ឋានមួយសម្រាប់ឈានទៅរកភាពលំអិតនាពេលខាងមុខ។

យើងខ្ញុំដែលជាអ្នករៀបរៀងកិច្ចការស្រាវជ្រាវនេះ សូមធ្វើការខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនាទាំងឡាយ នៅក្នុងកិច្ចការស្រាវជ្រាវនេះ ហើយក៏សូមអរគុណទុកជាមុនចំពោះ អ្នកគ្រូ មិត្តនិស្សិត និងប្រិយមិត្តទាំងអស់ដែលបានជួយផ្ដល់មតិកែលំអរដល់រូបយើងខ្ញុំផ្ទាល់ ដើម្បីឲកិច្ចការស្រាវជ្រាវលើកក្រោយៗកាត់តែល្អជាងនេះមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**

សារតាគម្រោង ..................................................................................................iv

## ជំពូកទី១
## ការរៀបចំផែនការគម្រោង

១.១. អំពីគម្រោង.................................................................................................... ១
១.២. គោលបំណង.................................................................................................... ១
១.៣. គោលដៅ........................................................................................................ ១
១.៤. សកម្មភាពសំខាន់ៗ ........................................................................................ ១
១.៥. ប្រភពថវិកា.......................................................................................................២
១.៦. អ្នកទទួលខុសត្រូវក្នុងគម្រោង.............................................................................៣
១.៧. សូចនាករ ....................................................................................................... ៤
១.៨. មធ្យោបាយផ្ទៀងផ្ទាត់.......................................................................................... ៦
១.៩. ហានិភ័យ........................................................................................................ ៨

## ជំពូកទី២
## ដំណើរការអនុវត្តន៍គម្រោង និងការជ្រើសរើសធនធានមនុស្ស

២.១. ការជ្រើសរើសធនធានមនុស្ស.............................................................................១១
២.២. ការបែងចែកធនធានមនុស្ស...............................................................................១១
២.២.១. ការរៀបចំអង្គការលេខ ..............................................................................១២
២.២.២. តួនាទី និងទំនួលខុសត្រូវ............................................................................១៣
២.២.៣ ការប្រើប្រាស់ពេលវេលា...............................................................................១៤
២.៤. ការប្រើប្រាស់ប្រធានគម្រោង .............................................................................១៦
២.៥. ការតាមដានគម្រោង វាយតម្លៃគម្រោង និងការតាមដានបន្ត ....................................១៦
២.៥.១. ការតាមដានគម្រោង ..................................................................................១៦
២.៥.២. ការវាយតម្លៃគម្រោង .................................................................................១៧
២.៥.៣. ការតាមដានបន្ត.........................................................................................១៨
២.៦. ការបញ្ចប់គម្រោង និងការផ្ទេរលទ្ធផលនៃគម្រោង......................................................១៨
២.៦.១. ការបញ្ចប់គម្រោង .......................................................................................១៨

២.៦.២. ការផ្ទេរលទ្ធផលនៃគម្រោង ......................................................................១៩

## ជំពូកទី៣
## ការវិភាគ SWOT លើដំណើរការអនុវត្តន៍គម្រោង

៣.១ ការវិភាគ SWOT នៃគម្រោង ......................................................................១៩
៣.១.១. ចំណុចខ្លាំង ......................................................................១៩
៣.១.២. ចំណុចខ្សោយ ......................................................................២០
៣.១.៣. ឱកាស ......................................................................២០
៣.១.៤. ការគំរាមកំហែង ......................................................................២១

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សាវតារគម្រោង

ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាបាននាំមកនូវការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះរបៀបរស់នៅ និងមុខរបររបស់ប្រជាពលរដ្ឋ។ ជាពិសេស នៅក្នុងរាជធានីភ្នំពេញ ការរីកចម្រើននៃប្រព័ន្ធដឹកជញ្ជូន និងការកើនឡើងនៃមធ្យោបាយធ្វើដំណើរទំនើបៗ បានធ្វើឱ្យរបរប្រពៃណីមួយចំនួនត្រូវប្រឈមនឹងការថយចុះជាបន្តបន្ទាប់។ ក្នុងចំណោមមុខរបរទាំងនោះ របរបើកស៊ីក្លូត្រូវបានចាត់ទុកថាជាមុខរបរប្រពៃណីដ៏សំខាន់មួយ ដែលមានទំនាក់ទំនងជាមួយប្រវត្តិសាស្ត្រ ការអភិវឌ្ឍទីក្រុង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ។

ស៊ីក្លូ គឺជាមធ្យោបាយដឹកជញ្ជូនប្រភេទកង់បី ដែលមានលក្ខណៈពិសេសដោយអ្នកដំណើរអង្គុយនៅផ្នែកខាងមុខ ខណៈអ្នកបើកបរអង្គុយ និងជិះកង់នៅផ្នែកខាងក្រោយ។ ស៊ីក្លូបានចូលមកប្រើប្រាស់នៅក្នុងតំបន់ឥណ្ឌូចិនក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៣០ ហើយភ្នំពេញត្រូវបានគេកត់ត្រាថាជាទីក្រុងមួយក្នុងចំណោមទីកន្លែងដំបូងៗដែលស៊ីក្លូត្រូវបានដាក់ឱ្យប្រើប្រាស់។ ប្រភពប្រវត្តិសាស្ត្រមួយចំនួនបានបង្ហាញថា ស៊ីក្លូមានវត្តមាននៅទីក្រុងភ្នំពេញនៅប្រហែលឆ្នាំ១៩៣៥–១៩៣៦ មុននឹងរីករាលដាលទៅកាន់តំបន់ផ្សេងទៀតក្នុងឥណ្ឌូចិន។

អ្នកប្រកបរបរបើកស៊ីក្លូភាគច្រើន គឺជាមនុស្សវ័យចំណាស់ដែលបានប្រកបរបរនេះអស់រយៈពេលជាច្រើនឆ្នាំ។ ដោយមើលឃើញពីតម្លៃប្រវត្តិសាស្ត្ររបស់ស៊ីក្លូ និងស្ថានភាពជីវភាពដែលអ្នកប្រកបរបរនេះអាចប្រឈម ជាពិសេសលោកតាស៊ីក្លូដែលនៅតែខិតខំប្រកបរបរប្រចាំថ្ងៃនៅតំបន់មុខវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ ក្រុមនិស្សិតបានផ្តួចផ្តើមរៀបចំគម្រោងសប្បុរសធម៌មួយដែលមានឈ្មោះថា «**មួយថ្ងៃ នៃស្នាមញញឹម**»។

ការបង្កើតគម្រោង «**មួយថ្ងៃ នៃស្នាមញញឹម**» មិនមានគោលបំណងផ្តល់ជំនួយតែផ្នែកសម្ភារៈ និងថវិកាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចង់បង្ហាញពីការយកចិត្តទុកដាក់ចំពោះមនុស្សវ័យចំណាស់ដែលនៅតែខិតខំប្រឹងប្រែងរកចំណូលតាមរយៈមុខរបរប្រពៃណី។ ជំនួយដែលផ្តល់ជូន ទោះបីជាមិនអាចដោះស្រាយបញ្ហាជីវភាពរបស់ពួកគាត់បានទាំងស្រុងក៏ដោយ ក៏អាចចូលរួមចំណែកកាត់បន្ថយបន្ទុកក្នុងរយៈពេលខ្លី និងផ្តល់កម្លាំងចិត្តដល់ពួកគាត់ផងដែរ។

ជាសរុប គម្រោង «**មួយថ្ងៃ នៃស្នាមញញឹម**» ត្រូវបានផ្តួចផ្តើមឡើងដោយផ្អែកលើការយល់ឃើញអំពីតម្លៃរបស់មុខរបរស៊ីក្លូក្នុងប្រវត្តិសាស្ត្រ និងសង្គមកម្ពុជា ព្រមទាំងការយកចិត្តទុកដាក់ចំពោះជីវភាពរបស់លោកតាស៊ីក្លូដែលនៅតែប្រកបរបរនេះ។ គម្រោងនេះសង្ឃឹមថា តាមរយៈការចូលរួមតូចមួយរបស់ក្រុមនិស្សិត នឹងអាចនាំមកនូវការចែករំលែកក្តីសង្ឃឹម ស្នាមញញឹម និងកម្លាំងចិត្តដល់លោកតាស៊ីក្លូ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌នៃការចែករំលែក និងការជួយគ្នាទៅវិញទៅមកនៅក្នុងសង្គម។

# ជំពូកទី១
# ការរៀបចំផែនការគម្រោង

## ១. ១ អំពីគម្រោង

គម្រោងនេះមានឈ្មោះថា៖ **កម្មវិធីសប្បុរសធម៌ «មួយថ្ងៃ នៃស្នាមញញឹម»**។

## ១.២. គោលបំណង

សម្រាប់គម្រោងមួយនេះដែរ គឺមានគោលបំណងធ្វើសប្បុរសធម៌ ចែករំលែកក្តីសង្ឃឹម និងស្នាមញញឹមជូនចំពោះលោកតាស៊ីក្លូ នៅមុខវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ តាមរយៈការផ្តល់អំណោយសប្បុរសធម៌ ជាថវិកា និងគ្រឿងឧបភោគបរិភោគដែលចាំបាច់។

## ១.៣. គោលដៅ

ដើម្បីសម្រេចឱ្យបាននូវគោលបំណងខាងលើនេះ គម្រោងបានកំណត់គោលដៅចំនួន ៣ជាចម្បង ដូចខាងក្រោម៖

**គោលដៅទី១** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**គោលដៅទី២** ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និង រៀបចំប្រគល់កញ្ចប់អំណោយជូន លោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**គោលដៅទី៣** សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៤. សកម្មភាពសំខាន់ៗ

ដើម្បីសម្រេចបាននូវគោលដៅនីមួយៗ នៃគម្រោងមួយនេះ យើងមានសកម្មភាពសំខាន់ៗមួយចំនួនសម្រាប់ ចូលរួមសម្រេចនូវគោលដៅទាំងបីខាងលើ ដែលមានដូចខាងក្រោម៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

- **សកម្មភាពទី១.១៖** រៀបចំក្រុមការងារដែលមានសមាជិក៦រូប ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។
- **សកម្មភាពទី១.២៖** ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

- **សកម្មភាពទី១.៣៖** ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន២០កញ្ចប់ សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**គោលដៅទី២៖** ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និង រៀបចំប្រគល់កញ្ចប់អំណោយជូន លោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

- **សកម្មភាពទី២.១៖** ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់ នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។
- **សកម្មភាពទី២.២៖** ក្រុមការងារ រៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០ កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។
- **សកម្មភាពទី២.៣៖** ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍ យ៉ាងតិចចំនួន១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**គោលដៅទី៣៖** សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

- **សកម្មភាពទី៣.១៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។
- **សកម្មភាពទី៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។
- **សកម្មភាពទី៣.៣៖** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៥. ប្រភពថវិកា

គម្រោងខាងលើនេះ ទទួលបានថវិកាគាំទ្រពីដៃគូសហការរួមមានខាងក្រោម៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។ កញ្ចប់ថវិកាឧបត្ថម្ភទទួលបានពីសំណាក់ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន ៥០០ ០០០រៀល សម្រាប់ប្រើប្រាស់ក្នុងចំណាយទូទៅ ចំណាយលើកញ្ចប់អំណោយ និងការវេចខ្ចប់។

**គោលដៅទី២៖** កញ្ចប់ថវិកាឧបត្ថម្ភ ពីសំណាក់សប្បុរសជន(តាមបណ្តាញសង្គម) ដែលចាប់អារម្មណ៍ជាមួយគម្រោងនេះ និងការចូលរួមពី អ្នកគ្រូ លោកគ្រូ រួមទាំងសិស្សច្បងសរុបជាថវិកាចំនួន ៥០០ ០០០រៀល សម្រាប់ប្រើប្រាស់ជាប្រាក់ឧបត្ថម្ភផ្ទាល់ ជូនក្រុមលោកតាស៊ីក្លូ។

**គោលដៅទី៣៖** ថវិកាបម្រុងរដ្ឋបាលគឺ ត្រូវដកចេញពី ៥% នៃថវិកាសរុបដែលបានកៀរគរបាន ដើម្បីទុកសម្រាប់ចំណាយលើការរៀបចំរបាយការណ៍ ការបោះពុម្ភ និងការបង់ថ្លៃសេវាសាធារណៈ ជូន ៥០ ០០០រៀល ហើយចំពោះថវិកាដែលនៅសេសសល់ពីកម្មវិធី ប្រសិនបើមានថវិកាសល់ពីការទិញសម្ភារៈ ត្រូវបង្វែរមកប្រើប្រាស់ក្នុងដំណាក់កាលវាយតម្លៃ និងរបាយការណ៍។

## ១.៦. អ្នកទទួលខុសត្រូវក្នុងគម្រោង

ដោយយោងតាម សមាជិកខាងក្រុមយើងខ្ញុំមានចំនួន៦នាក់ ហើយក៏ជាអ្នកទទួលបន្ទុកក្នុងគម្រោងមួយនេះផងដែរ។ ដូចនេះ អ្នកដែលទទួលខុសត្រូវ បានរៀបចំដូចខាងក្រោម៖

**គោលដៅទី១៖**

**សកម្មភាពទី១.១៖** រៀបចំក្រុមការងារដែលមានសមាជិក៦រូប ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.១ **លោក ថៃ សុមេធ**

**សកម្មភាពទី១.២៖** ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.២ **កញ្ញា ភី ចិន្តា**

**សកម្មភាពទី១.៣៖** ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន២០កញ្ចប់ សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.៣ **កញ្ញា គឹម ស្រីនិច្ច**

**គោលដៅទី២៖**

**សកម្មភាពទី២.១៖** ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់ នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.១ **លោក ណាំ សុខហៃ**

**សកម្មភាពទី២.២៖** ក្រុមការងារ រៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.២ **កញ្ញា មុត នីតា**

**សកម្មភាពទី២.៣៖** ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី២.៣ **កញ្ញា ជឹម សុភានូ**

**គោលដៅទី៣៖**

**សកម្មភាពទី៣.១៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី៣.១ **លោក ថៃ សុមេធ**

**សកម្មភាពទី៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោងនៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី៣.២ **កញ្ញា ភី ចិន្តា**

**សកម្មភាពទី៣.៣៖** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

អ្នកទទួលខុសត្រូវសម្រាប់សកម្មភាពទី១.១ **កញ្ញា គឹម ស្រីនិច្ច**

## ១.៧. សូចនាករ

សូចនាករសម្រាប់វាស់វែង នៅក្នុងគម្រោងនេះរួមមាន៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី១.១៖** រៀបចំក្រុមការងារដែលមានសមាជិក៦រូប ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។

**សូចនាករទី១.១.១៖** ក្រុមការងារមានសមាជិក៦រូប ត្រូវបានបង្កើតឡើង សម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។

**សកម្មភាពទី១.២៖** ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

**សូចនាករទី១.២.១៖** ក្រុមការងារត្រូវបានចុះសិក្សាដល់ទីតាំង ប្រមូលព័ត៌មានអំពីតម្រូវការសម្ភារៈ និងជួបពិភាក្សាជាមួយគ្រប់ភាគីពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

**សកម្មភាពទី១.៣៖** ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន២០កញ្ចប់ សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**សូចនាករទី១.៣.១៖** របាយការណ៍ពីការវេចខ្ចប់អំណោយ និងរូបថត នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**គោលដៅទី២៖** ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និងរៀបចំប្រគល់កញ្ចប់អំណោយជូនលោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.១៖** ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់ នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី២.១.១៖** អំណោយទាំងអស់ ត្រូវបានដឹកជញ្ជូនទៅដល់ទីតាំង ដោយសុវត្ថិភាព និងទាន់ពេលវេលា នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.២៖** ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី២.២.១៖** អំណោយចំនួន២០កញ្ចប់ ត្រូវបានជូនលោកតាស៊ីក្លូ ដោយជោគជ័យ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.៣៖** ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី២.៣.១៖** រូបភាព និងវីដេអូ នៃសកម្មភាពគម្រោង ត្រូវបានផ្តិតទុកជាអនុស្សាវរីយ៍ និងជាឯកសារ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**គោលដៅទី៣៖** សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.១៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី៣.១.១៖** របាយការណ៍បូកសរុបថវិកា ត្រូវបានសម្រេចជាស្ថាពរ ដោយមានភាពត្រឹមត្រូវ និងអាចផ្ទៀងផ្ទាត់ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី៣.២.១៖** របាយការណ៍បូកសរុបនូវលទ្ធផលនានា ត្រូវបានរៀបចំ និង បញ្ចប់ជាស្ថាពរ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.៣៖** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផល នៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**សូចនាករទី៣.៣.១៖** របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោង ត្រូវបាន សម្រេចជាស្ថាពរ និងមានខ្លឹមសារពេញលេញ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៨. មធ្យោបាយផ្ទៀងផ្ទាត់

មធ្យោបាយផ្ទៀងផ្ទាត់នៅក្នុងគម្រោងនេះរួមមាន៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី១.១៖** រៀបចំក្រុមការងារដែលមានសមាជិក៦រូប ដើម្បីគ្រប់គ្រង និងអនុវត្ត គម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.១.១៖** បញ្ជីឈ្មោះក្រុមការងារ និងអង្គការលេខ នៅត្រឹមសប្តាហ៍ ទី១ ខែកញ្ញា ឆ្នាំ២០២៦។

**សកម្មភាពទី១.២៖** ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែង របស់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.២.១៖** ក្រុមការងារធ្វើរបាយការណ៍ចុះសិក្សាទីតាំង បញ្ជី តម្រូវការសម្ភារៈ និងរូបថតឬវីដេអូនៃការចុះសិក្សា នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ ២០២៦។

**សកម្មភាពទី១.៣៖** ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន២០កញ្ចប់ សម្រាប់ ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី១.៣.១៖** ក្រុមការងារថតរូប និងមានរបាយការណ៍សកម្មភាព នៃការរៀបចំនិងវេចខ្ចប់ ដែលត្រឹមត្រូវទៅតាមបញ្ជីនៃចំនួនកញ្ចប់អំណោយ នៅត្រឹម សប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**គោលដៅទី២៖** ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និងរៀបចំប្រគល់កញ្ចប់អំណោយជូនលោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.១៖** ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់ នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.១.១៖** កំណត់ត្រា និងរូបថត ពីការទទួលទំនិញនៅទីតាំងកំណត់ និងបញ្ជីសម្ភារៈដែលបានដឹកជញ្ជូន នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.២៖** ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.២.១៖** ការរៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគទៅកាន់លោកតាស៊ីក្លូតាមបញ្ជីឈ្មោះ និងមានបញ្ជីប្រគល់-ទទួល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.៣៖** ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំ១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី២.៣.១៖** ក្រុមការងារផ្តិតយករូបភាព និងវីដេអូដែលបានថតទុកជាភស្តុតាងនៃការអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**គោលដៅទី៣៖** សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.១៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី៣.១.១៖** របាយការណ៍ត្រូវផ្អែកលើវិក្កយបត្រទូទាត់ បញ្ជីចំណូល-ចំណាយ និងតារាងសង្ខេបថវិកា នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី៣.២.១៖** របាយការណ៍បូកសរុបលទ្ធផលគម្រោង ឯកសារវាយតម្លៃលទ្ធផល និងភស្តុតាងគាំទ្រពាក់ព័ន្ធនឹងការអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.៣៖** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**មធ្យោបាយផ្ទៀងផ្ទាត់ទី៣.៣.១៖** លិខិតប្រគល់-ទទួលរបាយការណ៍ និងបញ្ជីអ្នកទទួល នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

## ១.៩. ហានិភ័យ

ការអនុវត្តគម្រោងសប្បុរសធម៌ នៅក្នុងរាជធានីភ្នំពេញ តម្រូវឱ្យមានការយល់ដឹងស៊ីជម្រៅអំពីបរិបទសង្គម ភូមិសាស្ត្រ និងបទប្បញ្ញត្តិច្បាប់ ខាងក្រោមនេះគឺជាការវិភាគហានិភ័យលម្អិតសម្រាប់សកម្មភាពនីមួយៗ៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និងរៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី១.១៖** រៀបចំក្រុមការងារដែលមានសមាជិក៦រូប ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦។

**ហានិភ័យទី១.១.១៖** មិនមានអ្នកស្ម័គ្រចិត្តគ្រប់គ្រាន់ ដើម្បីបំពេញការងារនេះ។

**សកម្មភាពទី១.២៖** ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦។

**ហានិភ័យទី១.២.១៖** ការប្រមូលព័ត៌មានមិនបានគ្រប់ជ្រុងជ្រោយ ឬព័ត៌មានដែលទទួលបានមិនឆ្លុះបញ្ចាំងពីតម្រូវការពិត ។

**សកម្មភាពទី១.៣៖** ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន២០កញ្ចប់ សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦។

**ហានិភ័យទី១.៣.១៖** កង្វះសម្ភារៈ ការឡើងថ្លៃទំនិញ ការបញ្ហាទិញយឺត ឬការរៀបចំមិនទាន់តាមពេលវេលា។

**គោលដៅទី២៖** ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និងរៀបចំប្រគល់កញ្ចប់អំណោយជូនលោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី២.១៖** ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់ នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី២.១.១៖** ការកកស្ទះចរាចរណ៍ អាកាសធាតុមិនអំណោយផល យានជំនិះខូច ឬការខូចខាតសម្ភារៈ។

**សកម្មភាពទី២.២៖** ក្រុមការងាររៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០ កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី២.២.១៖** ចំនួនអ្នកទទួលលើសការកំណត់ ការរៀបចំមិនមានសណ្តាប់ធ្នាប់ និងការមិនចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធ។

**សកម្មភាពទី២.៣៖** ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី២.៣.១៖** បញ្ហាឧបករណ៍ថត រូបភាពឬវីដេអូមិនគ្រប់ចំនួន និងគុណភាពរូបភាពមិនល្អ។

**គោលដៅទី៣៖** សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូន ទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**សកម្មភាពទី៣.១៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី៣.១.១៖** ទិន្នន័យចំណាយមិនគ្រប់គ្រាន់ និងកំហុសក្នុងការបូកសរុបថវិកា។

**សកម្មភាពទី៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី៣.២.១៖** ការខ្វះទិន្នន័យ ឯកសារមិនគ្រប់គ្រាន់ ប៉ះពាល់ដល់ការវាយតម្លៃរបស់គម្រោង។

**សកម្មភាពទី៣.៣៖** ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។

**ហានិភ័យទី៣.៣.១៖** ការប្រគល់របាយការណ៍មានភាពយឺតយ៉ាវ និងមិនសហការចូលរួមធ្វើរបាយការណ៍។

# ជំពូកទី២

# ដំណើរការអនុវត្តន៍គម្រោង និងការជ្រើសរើសធនធានមនុស្ស

## ២.១. ការជ្រើសរើសធនធានមនុស្ស

ក្រុមការងារចំនួន ០៦នាក់ ត្រូវបានជ្រើសរើសចេញពីក្រុមនិស្សិតថ្នាក់ជាន់ខ្ពស់ ជំនាន់២២ ជំហានទី២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយបានធ្វើការបែងចែកការទទួលខុសត្រូវរៀងៗខ្លួន។

## ២.២. ការបែងចែកធនធានមនុស្ស

ការបែងចែកធនធានមនុស្ស នៅក្នុងគម្រោងស្តីពី "**កម្មវិធីសប្បុរធម៌ មួយថ្ងៃ នៃស្នាមញញឹម**" មានសមាសភាពដូចខាងក្រោម៖

**ក. ប្រធានគម្រោង** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា៖

- គ្រប់គ្រង ដឹកនាំ និងជួយសម្របសម្រួលទៅដល់ក្រុមការងារ និងភាគីដែលពាក់ព័ន្ធក្នុងគម្រោងទាំងមូល។
- អនុម័តលើផែនការនានា ដូចជាផ្នែកហិរញ្ញវត្ថុ និងផែនការអនុវត្ត រួមទាំងត្រួតពិនិត្យ វាយតម្លៃលទ្ធផលគម្រោងផងដែរ។

**ខ. ផ្នែករៀបចំផែនការ** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា ៖

- បែងចែកភារកិច្ចការងារ និងរៀបចំតារាងពេលវេលា សម្រាប់សមាជិកម្នាក់ៗ។
- តាមដាន និងធ្វើរបាយការណ៍ អំពីវឌ្ឍនភាពនៃគម្រោងទៅកាន់ប្រធានគម្រោង។

**គ. ផ្នែកហិរញ្ញវត្ថុ** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា៖

- រៀបចំ និងតាមដានផែនការថវិកា និងការចំណាយផ្សេងៗ។
- ត្រួតពិនិត្យ និងរៀបចំរបាយការណ៍ថវិកា និងការចំណាយទៅកាន់ប្រធានគម្រោង។

**ឃ. ផ្នែកទំនាក់ទំនង និងសហប្រតិបត្តិការ** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា៖

- ទាក់ទងទំនាក់ទំនងទៅកាន់អាជ្ញាធរមូលដ្ឋាន និងអ្នកតំណាងសមាគមន៍លោកតាស៊ីក្លូ។
- ទាក់ទង និងផ្សព្វផ្សាយព័ត៌មានអំពីសប្បុរសជន និងប្រមូលប្រាក់ឧបត្ថម្ភ។

**ង. ផ្នែកកិច្ចការទូទៅ** មានកាតព្វកិច្ច និងទទួលខុសត្រូវដូចជា៖

- រៀបចំសម្ភារ ការដឹកជញ្ជូន និងសម្របសម្រួលទៅលើការរៀបចំកម្មវិធីទាំងមូល។

## ២.២.១. ការរៀបចំអង្គភាពលេខ

អង្គការលេខសម្រាប់គ្រប់គ្រង លើការអនុវត្តគម្រោងស្ដីអំពី **កម្មវិធីសប្បុរធម៌ មួយថ្ងៃ នៃស្នាមញញឹមជូនចំពោះលោកតាស៊ីក្លូនៅមុខវត្តឧណ្ណាលោម** ត្រូវបានរៀបរៀងឡើងដោយ៖

### អង្គការលេខនៃការគ្រប់គ្រងគម្រោងសប្បុរសធម៌ស្ដីអំពីមួយថ្ងៃ នៃស្នាមញញឹម




រៀបចំដោយ



លោក ណាំ សុខហៃ
ប្រធានផ្នែកកិច្ចការទូទៅ
កាលបរិច្ឆេទ៖ ០១/០៧/២០២៦

អនុម័តដោយ



លោក ថៃ សុមេត
ប្រធានផ្នែកកិច្ចការទូទៅ
កាលបរិច្ឆេទ៖ ០៦/០៧/២០២៦

### ២.២.២. តួនាទី និងទំនួលខុសត្រូវ

ក្រុមការងារចំនួន ០៦នាក់ បានធ្វើការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | តួនាទី | | ភារកិច្ចទទួលខុសត្រូវ |
|---|---|---|---|---|
| ១ | **លោក ថៃ សុមេធ** | ប្រធានគម្រោង | | -បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង<br>-ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល។ |
| ២ | **កញ្ញា ភី ចិន្តា** | ប្រធានផ្នែក | ផ្នែករៀបចំផែនការ | -ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈជាក់ស្តែងរបស់លោកតាស៊ីក្លូ<br>-ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង។ |
| ៣ | **កញ្ញា គីម ស្រីនិច្ច** | ប្រធានផ្នែក | ផ្នែកហិរញ្ញវត្ថុ | -ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន ២០កញ្ចប់សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ<br>-ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង។ |
| ៥ | **កញ្ញា មុត នីតា** | ប្រធានផ្នែក | ផ្នែកទំនាក់ទំនង និង សហប្រតិបត្តិការ | -ក្រុមការងារ រៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ។ |
| ៦ | **កញ្ញា ជឹម សុភានូ** | សមាជិក | | -ក្រុមការងារ ផ្តិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន១វីដេអូ នៃសកម្មភាពគម្រោង។ |
| ៤ | **លោក ណាំ សុខហៃ** | ប្រធានផ្នែក | ផ្នែកកិច្ចការទូទៅ | -ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០ កញ្ចប់ ទៅកាន់ទីតាំងដែលបានកំណត់។ |

## ២.២.៣ ការប្រើប្រាស់ពេលវេលា

| ល.រ | ផែនការសកម្មភាព | ចំនួនថ្ងៃ | ថ្ងៃចាប់ផ្ដើម | ថ្ងៃបញ្ចប់ | ខែកញ្ញា ឆ្នាំ ២០២៦ | | | | ខែតុលា ឆ្នាំ ២០២៦ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សប្តាហ៍ | | | | សប្តាហ៍ | | | |
| | | | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | បង្កើតក្រុមការងារ សិក្សាពីទីតាំងដែលត្រូវចុះ បង្កើតគម្រោងប្រមូលថវិកា និង រៀបចំគ្រឿងឧបភោគបរិភោគដែលត្រូវបរិច្ចាគ ចាប់ពីសប្ដាហ៍ទី១ ខែកញ្ញា ឆ្នាំ ២០២៦ ដល់ សប្ដាហ៍ទី១ ខែតុលា ឆ្នាំ២០២៦ | ៣៩ | ០១-០៩-២០២៦ | ១០-១០-២០២៦ | | | | | | | | |
| ១.១ | រៀបចំក្រុមការងារដែលមានសមាជិក៥រូប ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្ដាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ | ៥ | ០១-០៩-២០២៦ | ០៥-០៩-២០២៦ | | | | | | | | |
| ១.២ | ក្រុមការងារធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈដាក់ស្តែងរបស់លោកតាស៊ីក្លូ នៅត្រឹមសប្ដាហ៍ទី២ ខែកញ្ញា ឆ្នាំ២០២៦ | ៧ | ១៣-០៩-២០២៦ | ១៩-០៩-២០២៦ | | | | | | | | |
| ១.៣ | ក្រុមការងាររៀបចំ និងវេចខ្ចប់អំណោយចំនួន៣០កញ្ចប់ សម្រាប់ប្រគល់ជូន លោកតាស៊ីក្លូ នៅត្រឹមសប្ដាហ៍ទី៤ ខែកញ្ញា ឆ្នាំ២០២៦ | ១០ | ២០-០៩-២០៦ | ៣០-០៩-២០២៦ | | | | | | | | |
| ២ | ដឹកជញ្ជូនគ្រឿងឧបភោគបរិភោគទៅទីតាំងដែលបានកំណត់ និង រៀបចំប្រគល់កញ្ចប់អំណោយជូន លោកតាស៊ីក្លូ និងថតរូបទុកជាអនុស្សាវរីយ៍ នៅត្រឹមសប្ដាហ៍ទី ២ ខែតុលា ឆ្នាំ២០២៦ | ១៧ | ០១-១០-២០២៦ | ១៧-១០-២០២៦ | | | | | | | | |
| ២.១ | ក្រុមការងារ ដឹកជញ្ជូនឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់ទីតាំងដែលបាន កំណត់ នៅត្រឹមសប្ដាហ៍ទី១ ខែតុលា ឆ្នាំ២០២៦ | ១០ | ០១-១០-២០២៦ | ១០-១០-២០២៦ | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.២ | ក្រុមការងារ រៀបចំ និងប្រគល់កញ្ចប់ឧបភោគបរិភោគចំនួន ២០កញ្ចប់ ទៅកាន់លោកតាស៊ីក្លូ នៅត្រឹមសប្ដាហ៍ទី២ ខែតុលា ឆ្នាំ២០២៦។ | ៧ | ១១-១០-២០២៦ | ១៧-១០-២០២៦ | | | | | | | | |
| ២.៣ | ក្រុមការងារ ផ្ដិតយករូបភាពយ៉ាងតិច ៥០រូប និងវីដេអូអនុស្សាវរីយ៍យ៉ាងតិចចំនួន ១វីដេអូ នៃសកម្មភាពគម្រោង នៅត្រឹមសប្ដាហ៍ទី២ ខែតុលា ឆ្នាំ២០២៦ | ៧ | ១១-១០-២០២៦ | ១៧-១០-២០២៦ | | | | | | | | |
| ៣ | សរសេររបាយការណ៍អំពី ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦ | ៧ | ១៨-១០-២០២៦ | ២៤-១០-២០២៦ | | | | | | | | |
| ៣.១ | ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកាដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្ដាហ៍ទី២ ខែតុលា ឆ្នាំ២០២៦ | ៧ | ១១-១០-២០២៦ | ១៧-១០-២០២៦ | | | | | | | | |
| ៣.២ | ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្ដាហ៍ទី២ ខែតុលា ឆ្នាំ២០២៦ | ៧ | ១១-១០-២០២៦ | ១៧-១០-២០២៦ | | | | | | | | |
| ៣.៣ | ក្រុមការងារ ប្រគល់របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅកាន់អ្នកពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦ | ៧ | ២៥-១០-២០២៦ | ៣១-១០-២០២៦ | | | | | | | | |

## ២.៤. ការប្រើប្រាស់ប្រធានគម្រោង

ថវិការគម្រោងទទួលបានពីប្រភពថវិការទាំងពីរខាងលើនឹងត្រូវបែងចែកសម្រាប់ការងារផ្សេងៗ ដូចខាងក្រោម

| ល.រ | មុខទំនិញ | ចំនួន | តម្លៃឬឯកតា (រៀល) | សរុប (រៀល) | ភាគរយ | ភ្នាក់ងារឬមធ្យោបាយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | អង្ករ | ៤0kg | ៣ ៥០០ | ១៤០ ០០០ | | | សម្រាប់បរិភោគ |
| ២ | ត្រីខ | ២០ កំប៉ុង | ២ ៥០០ | ៥០ ០០០ | | | សម្រាប់បរិភោគ |
| ៣ | ទឹកស៊ីអ៊ីវ | ២០ដប | ៣ ០០០ | ៦០ ០០០ | | | សម្រាប់បរិភោគ |
| ៤ | ប្រេងកូឡា | ២០ខ្លង | ៣ ០០០ | ៦០ ០០០ | | | សម្រាប់លាប |
| ៥ | ក្រម៉ា | ២០ | ១០ ០០០ | ២០០ ០០០ | | | សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន |
| ៦ | អាវ | ២០ | | | | | ពីសប្បុរសជន |
| ៧ | សាប៊ូដុំ | ២០ដុំ | ២ ០០០ | ៤០ ០០០ | | | សម្រាប់ដុះខ្លួន |
| ៨ | **សរុបថវិកាសម្រាប់សម្ភារៈ** | | | **៥៥០ ០០០** | **៥៥%** | | |
| ៩ | ថវិកាឧបត្ថម្ភ | ២០នាក់ | ២០ ០០០ | ៤០០ ០០០ | ៤០% | | សម្រាប់ការចាយវាយ |
| ១០ | ថវិការបម្រុងរដ្ឋបាល | ៥% | ៥០ ០០០ | ៥០ ០០០ | ៥% | | របាយការណ៍ឬសេវាផ្សេងៗ |
| ១១ | **សរុបថវិកាគម្រោង ៨+៩+១០** | | | **១ ០០០ ០០០** | **១០០%** | | |

## ២.៥. ការតាមដានគម្រោង វាយតម្លៃគម្រោង និងការតាមដានបន្ត

### ២.៥.១. ការតាមដានគម្រោង

ការតាមដានជាប្រចាំ ទៅលើសកម្មភាពដែលបានកំណត់ក្នុងការអនុវត្ត ត្រូវតែដំណើរការទៅតាមផែនការ និងពេលវេលាកំណត់ ហើយត្រូវតាមដានដោយប្រធានគម្រោង សហការជាមួយសមាជិកទាំងអស់។ លើសពីនេះទៅទៀត ការតាមដានគម្រោងនេះ គឺដើម្បីធានាថា ដំណើរការនៅតែរលូនទៅតាមផែនការដែលបានដាក់ចេញឱ្យអនុវត្ត។

## ២.៥.២. ការវាយតម្លៃគម្រោង

ការវាយតម្លៃគម្រោង ត្រូវធ្វើឡើងនៅចុងបញ្ចប់នៃគម្រោង ដោយបុគ្គលឯករាជ្យ (តាមបណ្ដាញសង្គម) រៀបចំដោយប្រធានគម្រោង ដើម្បីតាមដាន និងវាយតម្លៃ។ ក្នុងន័យនេះ ប្រធានគម្រោងនឹងដឹកនាំកិច្ចប្រជុំពិនិត្យ និងវាយតម្លៃ ដែលកិច្ចប្រជុំនេះត្រូវវាយតម្លៃទៅលើលទ្ធភាពនៃសកម្មភាព ថាបានឆ្លើយតបទៅគោលបំណង និងការរំពឹងទុករបស់គម្រោងនេះ។ ជាមួយគ្នានេះ ការតាមដានគ្រប់ដំណាក់កាលទាំងអស់នៃគម្រោង នឹងត្រូវបានកត់ត្រាទុកជាឯកសារនិងវាស់ស្ទង់នូវកម្រិតពេញចិត្ត និងទាន់ពេលវេលានៃសកម្មភាពនីមួយៗ តាំងពីការចាប់ផ្ដើមគម្រោង រហូតដល់បញ្ចប់គម្រោង។

**ការវាយតម្លៃគម្រោង គឺធ្វើឡើងចំនួន ៤ដំណាក់កាល៖**

**១.ការវាយតម្លៃមុនអនុវត្ត**(Pre-Evaluation) គឺកំឡុងពេលការអង្កេតតម្រូវការសម្ភារៈ ការពិនិត្យធនធាន និងវិភាគលើបញ្ហាដែលអាចកើតមាន។

**២.ការវាយតម្លៃកំពុងអនុវត្ត**(On-going Evaluation) គឺកំឡុងពេលដំណើរការគ្រប់គ្រងសកម្មភាព ការដោះស្រាយបញ្ហាចំពោះមុខ ផ្ទៀងផ្ទាត់ការចំណាយលើសម្ភារៈឱ្យស្របតាមកញ្ចប់ថវិកា និងមធ្យោបាយធ្វើដំណើរឬដឹកជញ្ជូន។

**៣.ការវាយតម្លៃចុងក្រោយ** (End-Evaluation) គឺធ្វើឡើងភ្លាមៗបន្ទាប់ពីបញ្ចប់សកម្មភាព គឺការសម្រេចគោលដៅការពេញចិត្តពីអ្នកចូលរួម និងបូកសរុបចំណូល-ចំណាយសរុបភ្លាមៗក្រោយបញ្ចប់កម្មវិធី។

**៤.ការវាយតម្លៃក្រោយបញ្ចប់**(Post-Evaluation) គឺការវាយតម្លៃលើផលប៉ះពាល់ និងមេរៀនដែលទទួលបានគឺកត់ត្រានូវចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីទុកជាបទពិសោធន៍សម្រាប់គម្រោងក្រោយ និងធ្វើរបាយការណ៍លទ្ធផល និងរូបភាពទៅកាន់អ្នកបរិច្ចាក ដើម្បីបង្កើតទំនុកចិត្ត។

## ២.៥.៣. ការតាមដានបន្ត

ការតាមដានបន្ត ត្រូវធ្វើឡើងនៅពេលបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ក្នុងរយៈពេល១សប្ដាហ៍ ដោយប្រធានគម្រោង និងបុគ្គលឯករាជ្យ ដើម្បីតាមដានមើលនូវប្រសិទ្ធិភាព និងប្រសិទ្ធផលនៃគម្រោង ដែលបានអនុវត្ត ក្នុងគោលបំណងធានាថា អំណោយ និងសម្ភារៈដែលបានផ្ដល់ជូនលោកតាស៊ីក្លូ ត្រូវបានប្រើប្រាស់ស្របតាមគោលបំណង និងមានប្រយោជន៍កម្រិតណា ក៏ដូចជាសេចក្ដីពេញចិត្តរបស់លោកតាស៊ីក្លូ ។

## ២.៦. ការបញ្ចប់គម្រោង និងការផ្ទេរលទ្ធផលនៃគម្រោង

### ២.៦.១. ការបញ្ចប់គម្រោង

គម្រោងកម្មវិធីសប្បុរសធម៌ «**មួយថ្ងៃ នៃស្នាមញញឹម**» ជូនដល់លោកតាស៊ីក្លូ នៅមុខវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ មានរយៈពេល **៥៤**ថ្ងៃ ដោយគិតចាប់ពីសប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់សប្តាហ៍ទី៣ ខែតុលា ឆ្នាំ២០២៦។ គម្រោងសប្បុរសធម៌មួយនេះ បានសម្រេចគោលបំណងក្នុងការជួយផ្តល់ជាអំណោយសប្បុរសធម៌ ជាថវិកា និងគ្រឿងឧបភោគបរិភោគដែលចាំបាច់។ តាមរយៈការរៀបចំដោយមានផែនការ ការចូលរួមយ៉ាងសកម្មពីក្រុមការងារ ភាគីពាក់ព័ន្ធ សប្បុរសជន និងការអនុវត្តដែលមានប្រសិទ្ធភាព ក្រុមការងារគម្រោងនឹងទទួលបាននូវបទពិសោធន៍ និងចំណេះដឹងក្នុងការធ្វើផែនការគម្រោង រៀបចំចែករំលែកភារកិច្ចទទួលខុសត្រូវតាមធនធាន ការទំនាក់ទំនងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ និងការតាមដាន ព្រមទាំងវាយតម្លៃគម្រោងដោយផ្ទាល់។ ម្យ៉ាងទៀត សមាជិកគម្រោង នឹងទទួលបាននូវការស្វែងយល់ជាក់ស្តែងអំពីស្ថានភាពជីវភាពរបស់ក្រុមលោកតាស៊ីក្លូ និងរួមចំណែកក្នុងការជួយចែករំលែកក្តីសង្ឃឹម និងស្នាមញញឹមទៅកាន់ពួកគាត់ផងដែរ។

### ២.៦.២. ការផ្ទេរលទ្ធផលនៃគម្រោង

ក្រោយពីគម្រោងបានបញ្ចប់ ទិន្នន័យលទ្ធផលដែលប្រមូលបានពីការអនុវត្តគម្រោង ក្រុមការងារសម្រេចផ្ញើជូនអ្នកពាក់ព័ន្ធទាំងអស់នូវរបាយការណ៍របស់គម្រោង ដើម្បីធានាឱ្យបាននូវតម្លាភាពនៃគម្រោង។ លើសពីនេះទៅទៀត ដើម្បីជាឯកសារយោង និងព័ត៌មានទាក់ទងទៅនឹងស្ថានភាពជាក់ស្តែងរបស់លោកតាស៊ីក្លូ នៅមុខវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ សម្រាប់ជាគោលដៅសកម្មភាពសប្បុរសធម៌នាពេលអនាគត ក្រុមការងារនឹងផ្សព្វផ្សាយរបាយការណ៍របស់គម្រោងជាសាធារណៈ នៅលើគេហទំព័រផ្លូវការផ្ទាល់ខ្លួននីមួយៗ ដែលជាសមាជិកនៃគម្រោង និងក្នុងប្រព័ន្ធទំនាក់ទំនងសង្គមនានា។ ជាមួយនឹងការចែករំលែករបាយការណ៍នេះនឹងក្លាយជាគំរូ និងបំផុសគំនិតដល់អ្នកជំនាន់ក្រោយក្នុងការរៀបចំព្រមទាំងអនុវត្តសកម្មភាពសប្បុរសធម៌ក្នុងសង្គមនាអនាគត។

# ជំពូកទី៣

# ការវិភាគ SWOT លើដំណើរការអនុវត្តន៍គម្រោង

គម្រោងកម្មវិធីសប្បុរសធម៌ **«មួយថ្ងៃ នៃស្នាមញញឹម»** ជូនទៅដល់លោកតាស៊ីក្លូ នៅមុខវត្ត ឧណ្ណាលោម ក្នុងរាជធានីភ្នំពេញ ដែលមានការចូលរួមមូលនិធិសប្បុរសធម៌ពីសំណាក់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសគ្រប់គ្រង **ជំនាន់ទី២២ ជំហាន២** (MBM22-2B) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសប្បុរសជនដទៃ ដែលមានគោលបំណងធ្វើសប្បុរសធម៌ចែករំលែកក្តីសង្ឃឹម ស្នាមញញឹមជូនចំពោះលោកតាស៊ីក្លូ និងផ្តល់ជាកម្លាំងចិត្ត ដល់ពួកគាត់តាមរយៈការផ្តល់អំណោយសប្បុរសធម៌ ជាថវិកា និងគ្រឿងឧបភោគបរិភោគដែលចាំបាច់។ ជាមួយគ្នានេះដែរ ក្នុងការអភិវឌ្ឍគម្រោង ការវិភាគ SWOT លើដំណើរការអនុវត្តគម្រោងរួមមានដូចខាងក្រោម ៖

## ៣.១.១ ចំណុចខ្លាំង

- គោលបំណងច្បាស់លាស់ ៖ គម្រោងនេះ មានគោលបំណងច្បាស់លាស់ក្នុងការជួយសម្រាលការលំបាក និងផ្តល់ក្តីសង្ឃឹមដល់ក្រុមលោកតាដែលមានជីវភាពខ្វះខាត។ គម្រោងមានគោលដៅផ្តោតលើក្រុមលោកតាស៊ីក្លូ វាជួយឱ្យការរៀបចំសកម្មភាព ការបែងចែកធនធាន និងការវាយតម្លៃលទ្ធផល។
- ការបែងចែកក្រុមការងារគ្រប់គ្រងអនុវត្តៈ ការបង្កើតក្រុមការងារ ជួយឱ្យមានការបែងចែកការកិច្ចច្បាស់លាស់ ហើយជួយឱ្យការងារមានភាពងាយស្រួល និងប្រកបដោយរលូន។
- កាលវិភាគអនុវត្តគម្រោងមានរចនាសម្ព័ន្ធច្បាស់លាស់៖ គម្រោងមានការរៀបចំល្អជាមួយនឹងកាលបរិច្ឆេទកំណត់សម្រាប់សកម្មភាពនីមួយៗ ដែលវាជួយឱ្យក្រុមការងារ អាចគ្រប់គ្រងពេលវេលាឱ្យមានប្រសិទ្ធភាព និងគ្រប់គ្រងការអនុវត្តស្របតាមផែនការ។
- សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់៖ គម្រោងបានកំណត់សូចនាករសម្រាប់វាស់វែងលទ្ធផល និងមានមធ្យោបាយផ្ទៀងផ្ទាត់ ដូចជា របាយការណ៍ បញ្ជីចំណូល-ចំណាយ វិក្កយបត្រ រូបថត វីដេអូ និងបញ្ជីប្រគល់-ទទួល។
- ការប្រើប្រាស់ឯកសារ និងឧបករណ៍ជំនួយ៖ ប្រើប្រាស់ឯកសារយោង (របាយការណ៍ពាក់ព័ន្ធ រូបថត និង វីដេអូនៃសកម្មភាពគម្រោង) ដើម្បីបញ្ជាក់ថា សកម្មភាពបានអនុវត្តជាក់ស្តែង និងជួយបង្ហាញពីភាពមានទំនួលខុសត្រូវនៃគម្រោង ដើម្បីជាទំនុកចិត្តដល់ភាគីដែលពាក់ព័ន្ធ។

- ការទំនាក់ទំនង៖ សមាជិកគម្រោងបានទំនាក់ទំនងទៅក្រុមលោកតាស៊ីក្លូ មិត្តរួមថ្នាក់ រួមសាលា សាស្ត្រាចារ្យនៅសាលា បណ្ដាញសង្គម ដែលអាចជួយសម្រួលដល់ការរៀបចំផែនការ ប្រមូលមូលនិធិ និងអនុវត្តកម្មវិធីនៅនឹងទីតាំងផ្ទាល់។
- បេសកកម្មសប្បុរសធម៌៖ គម្រោងផ្ដោតលើការជួយសម្រួលដល់ជីវភាពលោកតាស៊ីក្លូដែលមានភាពខ្វះខាត ដែលវាមិនមែនត្រឹមតែជាបេសកកម្មដែលមានអត្ថន័យប៉ុណ្ណោះទេ វាថែមទាំងជួយទាក់ទាញសប្បុរសធម៌ឱ្យមានការចូលរួមកាន់តែច្រើន និងជំរុញឱ្យអ្នកស្ម័គ្រចិត្ត និងអ្នកឧបត្ថម្ភចូលរួមយ៉ាងសកម្មផងដែរ។

### ៣.១.២. ចំណុចខ្សោយ

- មូលនិធិសប្បុរសនៅមានកម្រិត៖ ដោយសារការប្រមូលមូលនិធិមានរយៈពេលខ្លី ដែលតម្រូវឱ្យកញ្ចប់អំណោយសប្បុរសធម៌ និងថវិកាឧបត្ថម្ភ នៅមានកម្រិតតិចតួច បើធៀបទៅនឹងកង្វះខាតជាក់ស្ដែងដែលគម្រោងបានស្វែងយល់។
- ពឹងផ្អែកលើសមាជិក៖ ការអនុវត្តសកម្មភាពត្រូវពឹងផ្អែកលើសមាជិក ប្រសិនបើសមាជិកណាម្នាក់មានការមមាញឹក មិនអាចចូលរួម ឬមិនបំពេញភារកិច្ចតាមការកំណត់ នោះអាចប៉ះពាល់ដល់កាលវិភាគ និងបង្កើនបន្ទុកដល់សមាជិកដទៃទៀត។
- ការទំនាក់ទំនងជាមួយសមាគមន៍លោកតាស៊ីក្លូ៖ អាចមានបញ្ហាភាសា ឬវប្បធម៌ ដែលអាចមានផលប៉ះពាល់ដល់ការយល់ដឹងអំពីតម្រូវការ និងការសម្របសម្រួលសកម្មភាពនានា។
- ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់គោលដៅ និងអាកាសធាតុ ៖ ស្ថានភាពផ្លូវនៅទីក្រុងមានភាពតូចចង្អៀត មានការកកស្ទះ និងស្ថានភាពអាកាសធាតុមិនអំណោយផលអាចបណ្ដាលឱ្យពន្យារពេលធ្វើសកម្មភាពនៃគម្រោង។

### ៣.១.៣. ឱកាស

- ពង្រឹងទំនាក់ទំនង ៖ បង្កើតភាពជិតស្និទ្ធរវាងក្រុមការងារគម្រោង និងផ្សារភ្ជាប់ទំនាក់ទំនងល្អជាមួយមិត្តរួមថ្នាក់។
- យុវជន និងសកម្មភាពសង្គម ៖ ផ្ដល់ឱកាស និងលើកទឹកចិត្តដល់ក្រុមយុវជនឱ្យចូលរួមការងារសង្គម។
- ការផ្សព្វផ្សាយ ៖ បង្ហាញសកម្មភាពវិជ្ជមាននៃការងារសង្គម ដែលអាចជម្រុញដល់អ្នកដែលមានចំណាប់អារម្មណ៍ចង់បរិច្ចាគនាពេលអនាគតអោយបានច្រើន ។

- ការអភិវឌ្ឍគម្រោងបន្តៈ ប្រសិនបើគម្រោងទទួលបានជោគជ័យ វាអាចក្លាយជាគំរូសម្រាប់ការរៀបចំគម្រោងសប្បុរសធម៌ផ្សេងៗទៀត។ ក្រុមការងារអាចប្រើប្រាស់បទពិសោធន៍ និងទិន្នន័យដែលទទួលបាន ដើម្បីកែលម្អការរៀបចំគម្រោងបន្ទាប់។

### ៣.១.៤. ការគំរាមកំហែង

- បញ្ហាចរាចរណ៍ និងការដឹកជញ្ជូនៈ ការដឹកជញ្ជូនអំណោយទៅកាន់ទីតាំងគោលដៅ អាចប្រឈមនឹងការកកស្ទះចរាចរណ៍ ផ្លូវតូចចង្អៀត ឬការលំបាកក្នុងការចូលទៅកាន់តំបន់គោលដៅ។
- លក្ខខណ្ឌសុវត្ថិភាព ៖ ការផ្តល់អំណោយនៅលើដងផ្លូវធ្វើដំណើរ និងមានការជួបជុំពីសំណាក់លោកតាស៊ីក្លូ អាចបង្កឱ្យមានការអសុវត្ថិភាពផ្សេងៗ។
- លក្ខខណ្ឌវប្បធម៌ និងការរស់នៅ ៖ វាអាចមានភាពខុសគ្នាខ្លះ រវាងក្រុមការងារ និងលោកតាស៊ីក្លូក្នុងតំបន់ដែលអាចនឹងអោយមានភាពភាន់ច្រឡំផ្សេងៗ។
- លក្ខខណ្ឌខ្វះទំនុកចិត្តនៃអ្នកបរិច្ចាគ ៖ អាចមានករណីមិនទុកចិត្ត ទៅលើការប្រើប្រាស់កញ្ចប់ថវិការក្នុងការទិញសម្ភារផ្សេងៗ ។
- អាកាសធាតុមិនអំណោយផលៈ ភ្លៀងខ្លាំង ឬអាកាសធាតុមិនអំណោយផល អាចប៉ះពាល់ដល់ការធ្វើដំណើរ ការប្រមូលផ្តុំ និងការថតរូបឬវីដេអូ សកម្មភាពអាចត្រូវពន្យារពេល។

# សេចក្តីសន្និដ្ឋាន

ក្រោយអនុវត្តគម្រោងមួយនេះបញ្ចប់ គម្រោងនេះបានបញ្ចប់ភាពជោគជ័យយ៉ាងច្បាស់លាស់ទាំងនៅក្នុងការធ្វើផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃគម្រោង។ ម្យ៉ាងវិញទៀត ការចូលរួមយ៉ាងសកម្មពីសមាជិកក្រុម និងការគាំទ្រពីសមាគមន៍លោកតាស៊ីក្លូ គឺជាសូចនាករះឥទ្ធិពលវិជ្ជមានទៅកាន់ក្រុមលោកតាស៊ីក្លូ ដែលជាគោលដៅនៃគម្រោង។

លទ្ធផលវិជ្ជមានដែលទទួលបានពីគម្រោងមួយនេះ មានដូចជា ៖

- ការផ្តល់អំណោយសប្បុរសធម៌ ជាថវិកា និងគ្រឿងឧបភោគបរិភោគ បង្កើតទំនាក់ទំនង និងបង្កើននូវស្នាមញញឹម បរិយាកាសរីករាយ និងទំនាក់ទំនងល្អជាមួយសមាគមន៍លោកតាស៊ីក្លូ
- ការលើកកម្ពស់សមត្ថភាពការងារជាក្រុម និងភាពដឹកនាំ នៅក្នុងសហគមន៍ជាក់ស្តែង
- បន្ថែមលើសពីនេះទៅទៀត គម្រោងមួយនេះ៖ បានផ្តល់ឱកាសដល់ក្រុមនិស្សិត ក្នុងការអនុវត្ត និងបង្កើនចំណេះដឹងក្នុងការរៀបចំនិងគ្រប់គ្រងគម្រោង ការអភិវឌ្ឍជំនាញទំនាក់ទំនង និងភាពជាអ្នកដឹកនាំ។ បើទោះជាមានឧបសគ្គខ្លះៗ គន្លងដំណើរការគម្រោងដូចដែលបានរៀបរាប់ខាងលើ ក៏ក្រុមសមាជិករបស់គម្រោងនៅតែបន្តការងារ និងបញ្ចប់ទៅបានយ៉ាងរលូន ។

សរុបសេចក្តីមក គម្រោងមួយនេះបានបង្ហាញពី ការរៀបចំការងារជាក្រុម ដែលធ្វើឱ្យចេញជាការស្ម័គ្រចិត្តរបស់ក្រុមសមាជិកគ្រប់រូប ដែលអាចជាជំនួយមួយផ្នែក ដល់លោកតាស៊ីក្លូ ជាពិសេសការងារមួយនេះបានឆ្លុះបញ្ចាំង និងជាគំរូសម្រាប់គម្រោងសប្បុរសធម៌ផ្សេងៗទៀតនាពេលអនាគត។